**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញមុខងាររបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាននះ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឲ្យឯកឧត្តម ឧត្តមនាវីឯក Sithawat Wongsuwan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកច្បាប់ នីតិវិធីតុលាការ និងកិច្ចការសន្តិសុខ នៃព្រះរាជាណាចក្រថៃឡង់ដ៍ ចូលជួបសម្តែងការគួរសម

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាខាងមុខព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូន ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា (ព្រះរាជពិធីប្រទានភ្លើងជ័យ) និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចុះពិនិត្យទិដ្ឋភាពនៃការហ្វឹកហាត់សមរបស់ក្រុមកីឡាករទូកងត្រៀមចូលរួមប្រកួតក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋ និងអាជ្ញាធរ នៅសង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសព លោកជំទាវ **លន់ ចន្ទរស្មី** នៅវត្តទួលទំពូង រាជធានីភ្នំពេញ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៨២ច្បាប់ ។

**១.២.ឯកឧត្តម ង៉ែ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន២១៧នាក់ និងស្មៀនឃុំ សង្កាត់ ចំនួន១០០នាក់ មកពីទូទាំងខេត្តតាកែវ និងបង្ហាញបេក្ខភាពដែលនឹងត្រូវឈរឈ្មោះជាសមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដោយមានការអញ្ជើញចូលរួមពីសមាជិកព្រឹទ្ធសភា រដ្ឋសភា ទីប្រឹក្សាឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ប្រធានក្រុមប្រឹក្សាខេត្ត ថ្នាក់ដឹកនាំជុំវិញខេត្ត និងអភិបាលខេត្តតាកែវ កែប និងខេត្តកំពត

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦០ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារសិក្សា០១ខ្នង មាន០៥បន្ទប់ដែលជាអំណោយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ជូនដល់អនុវិទ្យាល័យព្រះពុទ្ធ នៅឃុំព្រះពុទ្ធ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

-អញ្ជើញជាអធិបតី ក្នុងពិធីជប់លៀងជាកិត្តិយសជូនដល់គណៈប្រតិភូរដ្ឋសភានីតិប្បញ្ញត្តិជាតិ នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឯកឧត្តម ឧត្តមនាវីឯក Sithawat Wongsuwan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកច្បាប់ នីតិវិធីតុលាការ និងកិច្ចការសន្តិសុខ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតី ក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អនុញ្ញាតឲ្យគណៈប្រតិភូក្រុមមិត្តភាពឡាវ-កម្ពុជា ដឹកនាំដោយ ឯកឧត្តម ឧត្តម-សេនីយ៍ឯក **សែងនួន សៃញ៉ាក់ឡាត** អនុប្រធានសភាជាតិឡាវ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ព្រមទាំងជប់លៀងជាកិត្តិយសជូនគណៈប្រតិភូ និងទស្សនាការសម្តែងសិល្បៈចម្រុះកម្ពុជា-ឡាវ ដើម្បីអបអរទិវាបង្កើតទំនាក់ទំនងការទូតលើកទី៦១ រវាងកម្ពុជា-ឡាវ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា (ព្រះរាជពិធីប្រទានភ្លើងជ័យ) និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញទទួលគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌថ្នាក់មហាសេរីវឌ្ឍន៍ **ពីសម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបរំលឹកគុណ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ** នៅខេត្តព្រៃវែង

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក:**

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើ៖

១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរី ស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេង បន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួន នៃប្រទេសប៊្រុយណេដារូសាឡឹម ស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្ទំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

៥.កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៣

៦.ពិនិត្យ និងសម្រេចអំពីកាតព្វកិច្ចពាក់ព័ន្ធនឹងព្រឹទ្ធសភាក្នុងការអនុវត្តសាលដីកាលេខៈ ៣២០(ឧ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :**

ក្នុងខែវិច្ឆិកានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៣.១.មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់ ។

**៣.២.មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញចុះបេសកកម្ម ដើម្បីជួបសំណេះសំណាលផ្លាស់ប្តូរយោបល់រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងខេត្តនីមួយៗ ដើម្បីស្វែងរកដំណោះស្រាយ និងចំណុចល្អៗសម្រាប់បំពេញសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត

-អញ្ជើញចុះជួបសំណេះសំណាល និងផ្សព្វផ្សាយលទ្ធផលនៃសន្និសីទលើកទី៦ នៃគណៈកម្មាធិការកិច្ចការបរទេសនៃសភាប្រទេសកម្ពុជា ឡាវ វៀតណាម នៅទីក្រុងវៀងច័ន្ទប្រទេសឡាវ ជូនដល់ថ្នាក់ដឹកនាំនៃខេត្ត ក្រុង ស្រុក បណ្តាមន្ទីរជុំវិញខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៃខេត្តមណ្ឌលគិរី។

**៣.៣.មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៣ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យ

បណ្តឹងរបស់ស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន ០៩ករណី ព្រមទាំងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣ករណី

-អញ្ជើញចូលរួមប្រជុំ និងធ្វើរបាយការណ៍ស្តីពី លទ្ធផលនៃការចូលរួមប្រជុំ (IPU) នៅប្រទេសរុស្ស៊ី ដើម្បីជូន **សម្តេចប្រធានព្រឹទ្ធសភា**

-អញ្ជើញចូលរួមប្រជុំត្រួតពិនិត្យអំពី លទ្ធផលការងារក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងផ្សព្វផ្សាយសភាពការណ៍សំខាន់ៗជូនដល់គណៈអភិបាល ក្រុមប្រឹក្សាខណ្ឌ សង្កាត់ និងអធិការនគរបាល នៅខណ្ឌទួលគោក

-អញ្ជើញបើកអង្គប្រជុំគ្រូគង្វាលតំណាងនិកាយប្រូតេស្តង់ ប្រចាំខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប ក្នុងការរៀបចំខ្លួនទទួលគ្រូពេទ្យអន្តរជាតិដើម្បីទៅពិនិត្យជំងឺ និងចែកថ្នាំជូនប្រជាពលរដ្ឋដោយមិនគិតប្រាក់ នៅព្រះវិហារជីវិតថ្មី

-អញ្ជើញជួបពិភាក្សាការងារ ព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងការងារសង្គមជាមួយព្រះភទ្ទបណ្ឌិតោ **ភិន វុទ្ធី** ព្រះគ្រូចៅអធិការវត្តបុរាណនិវេសន៍ ហៅវត្តប្រាសាទនាងខ្មៅ ស្ថិតនៅភូមិចារ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ

-អនុញ្ញាតឲ្យកញ្ញា **និត នីតិការ** ជានិស្សិតបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតនីតិជំនួញ និងពន្ធដារ នៅប្រទេសបារាំង ចូលជួបសម្តែងការគួរសម និងបានផ្តល់អនុសាសន៍ឲ្យខិតខំរៀនសូត្រអំពីកិច្ចការសភា មុនពេលដែលកញ្ញាត្រូវទៅចូលរួមវគ្គសិក្សាស្តីពីយុវជនសភា នៅសភាសហព័ន្ធវ៉ាឡូនីប្រ៊ុចសែល (PFWB) នៃប្រទេសប៊ែលហ្ស៊ិក

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន១៣៣លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១០២លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **ទី បូរ៉ាស៊ី** ឯកឧត្តម **ឈិត គីមយាត** ឯកឧត្តម **ថុង ចន់** និងលោកជំទាវ **ឈូក ឈឹម** អញ្ជើញទៅទស្សនកិច្ចសិក្សា និងដកស្រង់បទពិសោធន៍ការងារនៅសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី២ និង មហាសន្និបាតលើកទី១០របស់សភាតំបន់អាស៊ី(APA) នៅទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួកគី

-ឯកឧត្តម **ប៊ូ ថង** អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ប្រាស៊ីត សាយ៉ាស៊ីត** ឯកអគ្គរដ្ឋទូតឡាវ មកទស្សនកិច្ចមិត្តភាព និងសម្តែងសិល្បៈចម្រុះឡាវ-កម្ពុជា នៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី នៅស្ថានទូតឡាវ រាជធានីភ្នំពេញ

-ឯកឧត្តម **ម៉ុង ឫទ្ធី** អនុញ្ញាតឲ្យឯកឧត្តម Takahashi Fumiaki អតីតឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក Hideaki Aratani រួមជាមួយសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគនៅកម្ពុជា

-ឯកឧត្តម **ជា ជេដ្ឋ** អនុញ្ញាតឲ្យលោកបណ្ឌិត Gunnar Fors ប្រធានផ្នែកស្រាវជ្រាវនៃរដ្ឋសភា ប្រទេសស៊ុយអ៊ែត និងថ្នាក់ដឹកនាំនៃវិទ្យាស្ថានសភាកម្ពុជា (PIC) ចូលជួបពិភាក្សាការងារដោយផ្តោតសំខាន់លើលទ្ធផល និងបញ្ហាប្រឈម បន្ទាប់ពីបានបំពេញទស្សនកិច្ចសិក្សានៅប្រទេសស៊ុយអ៊ែតកន្លងមក ដែលពាក់ព័ន្ធទៅនឹងការងាររៀបចំថវិកា និងសវនកម្ម ។/.

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែធ្នូ គ.ស២០១៧

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ